**ឧបសម្ព័ន្ធ២**

ភ្ជាប់នឹងប្រកាសលេខ០៤៧ ព.ណ. នច.ប្រក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥
ស្តីពីនីតិវិធីក្នុងការស្នើសុំ និងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ
សម្រាប់ការនាំចេញទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក

# នីតិវិធីប្រតិបត្តិស្តង់ដា សម្រាប់ការអនុវត្តប្រកាស

# ស្តីពី

# នីតិវិធីស្នើសុំ និងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ សម្រាប់ការនាំចេញទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក

# មាតិកា


**គោលបំណង** ..................... ១

**វិសាលភាព** ..................... ១

**ជំពូក១៖ កាតព្វកិច្ចទាក់ទងនឹងការនាំចេញ និងការផ្លាស់ប្តូរទិន្នន័យ** ..................... ១

១.១. ការចុះឈ្មោះស្នើសុំនាំចេញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម (CO Automation System) ..................... ១

១.២. នីតិវិធីនៃការចុះត្រួតពិនិត្យលើកដំបូង និងបន្តបន្ទាប់ ..................... ២

១.២.១. ការចុះត្រួតពិនិត្យលើកដំបូង ..................... ២

១.២.២. លក្ខខណ្ឌនៃការចុះត្រួតពិនិត្យ ..................... ២

១.៣. លក្ខខណ្ឌ និងឯកសារតម្រូវសម្រាប់ស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ..................... ២

១.៤. លក្ខខណ្ឌ និងឯកសារតម្រូវក្នុងការបញ្ចូលទិន្នន័យនៃវត្ថុធាតុដើមផលិតក្នុងស្រុក ..................... ៣

១.៥. ការផ្លាស់ប្តូរទិន្នន័យ ..................... ៣

១.៦. កាតព្វកិច្ចរបស់ផលិតករ និងអ្នកនាំចេញ ..................... ៣

**ជំពូក២៖ ក្រមសីលធម៌ វិន័យ និងបច្ចេកទេសវិជ្ជាជីវៈ នៃមន្ត្រីទទួលបន្ទុកអនុវត្តនីតិវិធី ពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ** ..................... ៤

២.១. ក្រមសីលធម៌របស់មន្ត្រីទទួលបន្ទុកអនុវត្តនីតិវិធីក្នុងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ . ៤

២.១.១. ក្រមសីលធម៌ និងវិន័យ ..................... ៤

២.១.២. បច្ចេកទេសវិជ្ជាជីវៈ ..................... ៤

២.១.២.១.តួនាទីនិងភារកិច្ចរបស់មន្ត្រីទទួលបន្ទុកចុះពិនិត្យ និងផ្ទៀងផ្ទាត់ ..................... ៤

២.១.២.២.តួនាទីនិងភារកិច្ចរបស់មន្ត្រីទទួលបន្ទុកចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ..................... ៤

២.២. ឯករាជ្យភាព និងទំនាស់ផលប្រយោជន៍ ..................... ៥

២.៣. រក្សាការសម្ងាត់ ..................... ៥

២.៤. ក្រមសីលធម៌របស់ផលិតករ និងអ្នកនាំចេញ ..................... ៥

**ជំពូក៣៖ នីតិវិធីនៃការចុះត្រួតពិនិត្យ និងការស៊ើបអង្កេត** ..................... ៥

៣.១. ការចុះត្រួតពិនិត្យលើកដំបូង ..................... ៦

៣.២. ការចុះត្រួតពិនិត្យ និងការស៊ើបអង្កេត ..................... ៦

៣.៣. ចំនួនដងនៃការចុះត្រួតពិនិត្យ ..................... ៦

៣.៤. ការជូនដំណឹងទៅផលិតករ និង/ឬអ្នកនាំចេញអំពីការចុះត្រួតពិនិត្យ ..................... ៦

៣.៥. លក្ខខណ្ឌនៃការចុះត្រួតពិនិត្យ និងស៊ើបអង្កេត ..................... ៦

៣.៦. សិទ្ធិរបស់មន្ត្រីស៊ើបអង្កេត ..................... ៦

៣.៧. នីតិវិធីនៃការចុះស៊ើបអង្កេត ..................... ៦

៣.៨. ការអនុវត្តលើបទល្មើសជាក់ស្តែងដែលរកឃើញក្នុងពេលចុះស៊ើបអង្កេត ..................... ៧

៣.៩. ការរក្សាការសម្ងាត់នៃព័ត៌មាន ..................... ៧

៣.១០. ប្រតិបត្តិការក្រោយការចុះស៊ើបអង្កេត ..................... ៧

៣.១១. វិធានការបន្តក្រោយការចុះស៊ើបអង្កេត ..................... ៧

៣.១២. ទណ្ឌកម្មរដ្ឋបាល ..................... ៧

## គោលបំណង

នីតិវិធីប្រតិបត្តិស្តង់ដានេះ មានគោលបំណងកំណត់នូវស្តង់ដាប្រតិបត្តិ ដោយយកចិត្តទុកដាក់ខ្ពស់លើការនាំចេញ គណនេយ្យភាព និងតម្លាភាពនៃការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ដោយមន្ត្រីនៃក្រសួងពាណិជ្ជកម្ម។ គោលបំណងនៃនីតិវិធីប្រតិបត្តិស្តង់ដានេះផងដែរ ជាឯកសារសម្រាប់លើកកម្ពស់ការនាំចេញទំនិញពីប្រទេសកម្ពុជាប្រកបដោយក្រមសីលធម៌ ការអនុលោមតាមច្បាប់ ភាពជឿជាក់ និងនិរន្តរភាពក្នុងពាណិជ្ជកម្មអន្តរជាតិ ដោយបង្កើនប្រសិទ្ធភាពដើម្បីទទួលបានជោគជ័យយូរអង្វែង និងរក្សាកេរ្តិ៍ឈ្មោះជាវិជ្ជមានរបស់ផលិតករ និងអ្នកនាំចេញ រួមទាំងសហគមន៍ធុរកិច្ចកម្ពុជានៅលើទីផ្សារពិភពលោក។

នីតិវិធីប្រតិបត្តិស្តង់ដានៃការបញ្ជាក់ដើមកំណើតទំនិញ ត្រូវបានសម្រេចដាក់ឱ្យអនុវត្តដើម្បីធានាពីតម្លាភាព និងប្រសិទ្ធភាពនៃការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ និងជំរុញការនាំចេញ ប្រកបដោយការទទួលខុសត្រូវនិងវិជ្ជាជីវៈដែលមានក្រសួងពាណិជ្ជកម្មជាសេនាធិការរបស់រាជរដ្ឋាភិបាល។ ចំពោះផលិតករ និងអ្នកនាំចេញទាំងអស់ ត្រូវអនុវត្តលក្ខខណ្ឌ និងកាតព្វកិច្ចនានាក្នុងសកម្មភាពនៃការស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ និងការនាំចេញជាមួយបណ្តាភាគីដែលពាក់ព័ន្ធ ដោយប្រកាន់ខ្ជាប់នូវសីលធម៌ គុណភាព និងអនុលោមភាពតាមស្តង់ដាច្បាប់។

## វិសាលភាព

នីតិវិធីប្រតិបត្តិស្តង់ដានៃការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ មានវិសាលភាពអនុវត្តចំពោះទំនិញមួយចំនួន ដូចមានក្នុងឧបសម្ព័ន្ធ១ នៃប្រកាសស្តីពីនីតិវិធីស្នើសុំ និងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ សម្រាប់ការនាំចេញទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក។

## ជំពូក១៖ កាតព្វកិច្ចទាក់ទងនឹងការនាំចេញ និងការផ្លាស់ប្តូរទិន្នន័យ

### ១.១. ការចុះឈ្មោះស្នើសុំនាំចេញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម (CO Automation System)

សម្រាប់ផលិតករ និងអ្នកនាំចេញ ដែលពុំធ្លាប់ចុះឈ្មោះក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ត្រូវស្នើសុំចុះឈ្មោះប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មតាមរយៈគេហទំព័រ https://co.moc.gov.kh/[1] របស់ក្រសួងពាណិជ្ជកម្ម មុននឹងមានសិទ្ធិស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ដោយបញ្ចូលព័ត៌មាន និងឯកសារតម្រូវទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជាទម្រង់ PDF ដូចខាងក្រោម៖

- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
- លិខិតប្រគល់សិទ្ធិជាតំណាងពីប្រធានក្រុមហ៊ុន ឬនាយកគ្រប់គ្រងក្នុងការចុះឈ្មោះ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងរូបថតទំហំ ៤×៦ របស់អ្នកប្រគល់និងទទួលសិទ្ធិ។

ចំពោះផលិតករ និងអ្នកនាំចេញ ដែលបានចុះឈ្មោះក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម មិនតម្រូវឱ្យចុះឈ្មោះប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មម្តងទៀតឡើយ។

---

[1] ផលិតករ និងអ្នកនាំចេញក៏អាចស្កេន QR Code ដើម្បីចូលទៅកាន់ប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម។

### ១.២. នីតិវិធីនៃការចុះត្រួតពិនិត្យលើកដំបូង និងបន្តបន្ទាប់

ដើម្បីធានាសង្គតិភាពជាមួយវិធានដើមកំណើតទំនិញ មន្ត្រីចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ត្រូវចុះត្រួតពិនិត្យលើកដំបូង យ៉ាងយូរ ២៤ម៉ោងនៃម៉ោងធ្វើការ បន្ទាប់ពីការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ឬ៤៨ម៉ោងនៃម៉ោងធ្វើការ សម្រាប់បណ្តាអាជីវកម្មដ្ឋាន ឬទីតាំងផលិតដែលនៅឆ្ងាយពីរាជធានីភ្នំពេញ។

#### ១.២.១. ការចុះត្រួតពិនិត្យលើកដំបូង

ការចុះត្រួតពិនិត្យនៅតាមអាជីវកម្មដ្ឋាន ឬទីតាំងផលិត ត្រូវអនុវត្តដោយមន្ត្រីជំនាញនៃក្រសួងពាណិជ្ជកម្ម។

#### ១.២.២. លក្ខខណ្ឌនៃការចុះត្រួតពិនិត្យ

មន្ត្រីជំនាញនៃក្រសួងពាណិជ្ជកម្ម ដែលទទួលការចាត់តាំងបំពេញភារកិច្ចចុះត្រួតពិនិត្យនៅតាមអាជីវកម្មដ្ឋាន ឬទីតាំងផលិត មានសិទ្ធិនិងអំណាចដូចខាងក្រោម៖

- ពិនិត្យអាជីវកម្មដ្ឋានឬទីតាំងផលិត និងកន្លែងប្រមូលទិញឬឃ្លាំងស្តុកទំនិញ
- ពិនិត្យឯកសារនាំចេញ៖
    - លិខិតបញ្ជាទិញ ( Purchase Order )
    - វិក្កយបត្រ និងតារាងវេចខ្ចប់ ( Invoice and Packing List ) និង
    - តារាងលម្អិតថ្លៃដើមផលិតផល ( Cost Breakdown )
- ពិនិត្យវត្ថុធាតុដើមក្នុងឃ្លាំង
- ពិនិត្យខ្សែប្រវាក់ផលិតកម្ម៖
    - ចំនួនកម្មករ និងតារាងបើកប្រាក់បៀវត្ស
    - វត្ថុធាតុដើមប្រើប្រាស់
    - ចំនួនម៉ាស៊ីន និងសមត្ថភាពផលិត ( Output Capacity )
    - បរិមាណផលិតផលសម្រេចសម្រាប់នាំចេញ
    - ស្លាកសញ្ញាលើផលិតផល ( ឧទាហរណ៍៖ Made in Cambodia ) និង
    - របាយការណ៍ផលិតកម្ម ( Production Record )។

ក្រោយការត្រួតពិនិត្យលើឯកសារពាក់ព័ន្ធខាងលើ មន្ត្រីជំនាញនៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើរបាយការណ៍ពិនិត្យទំនិញនាំចេញលើកដំបូង។ របាយការណ៍នេះ ជាកម្មវត្ថុនៃការអនុម័តចេញនូវលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញលើកដំបូង និងបន្តបន្ទាប់។

### ១.៣. លក្ខខណ្ឌ និងឯកសារតម្រូវសម្រាប់ស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ

ផលិតករ និង/ឬអ្នកនាំចេញ ដែលបានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មរួចហើយ អាចដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម និងត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- វិក្កយបត្រ និងតារាងវេចខ្ចប់
- តារាងលម្អិតថ្លៃដើមផលិតផល ឬឯកសារយោងតាមការកំណត់របស់វិធានដើមកំណើតទំនិញ
- របាយការណ៍របស់មន្ត្រីជំនាញក្រសួងពាណិជ្ជកម្មស្ដីពីការត្រួតពិនិត្យទំនិញនាំចេញលើកដំបូង។

### ១.៤. លក្ខខណ្ឌ និងឯកសារតម្រូវក្នុងការបញ្ចូលទិន្នន័យនៃវត្ថុធាតុដើមផលិតក្នុងស្រុក

ផលិតករ និង/ឬអ្នកនាំចេញ ត្រូវបញ្ចូលទិន្នន័យនៃវត្ថុធាតុដើមផលិតក្នុងស្រុក មកនាយកដ្ឋាននាំចេញនាំចូល ដោយភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖

- ច្បាប់ចម្លងកិច្ចសន្យាទិញ-លក់វត្ថុធាតុដើម
- វិក្កយបត្រ និងតារាងវេចខ្ចប់
- របាយការណ៍របស់មន្ត្រីនៃក្រសួងពាណិជ្ជកម្មស្ដីពីការត្រួតពិនិត្យខ្សែប្រវាក់ផលិតកម្មនៃរោងចក្រផ្គត់ផ្គង់។

### ១.៥. ការផ្លាស់ប្ដូរទិន្នន័យ

អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្លាស់ប្ដូរទិន្នន័យពាក់ព័ន្ធនឹងការនាំចេញនាំចូល។

### ១.៦. កាតព្វកិច្ចរបស់ផលិតករ និងអ្នកនាំចេញ

ផលិតករ និង/ឬអ្នកនាំចេញ ដែលជាអាជីវកម្មបានចុះបញ្ជីត្រឹមត្រូវ និងមានលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញដែលចេញដោយក្រសួងពាណិជ្ជកម្ម ត្រូវចាំបាច់អនុវត្តកាតព្វកិច្ច ដូចខាងក្រោម៖

- ធ្វើអាជីវកម្មដោយសុចរិតភាព ភាពស្មោះត្រង់ តម្លាភាព ដោយមិនបង្កើតភាពភាន់ច្រឡំទាក់ទងនឹងគុណភាព ប្រភពនិងស្លាកសញ្ញាសម្គាល់នៃផលិតផលនាំចេញឡើយ
- ធានាចំពោះអ្នកបញ្ជាទិញថា អនុលោមតាមវិធានដើមកំណើតទំនិញនៃប្រទេសនាំចូល ដោយមិនយកផលិតផលសម្រេច ឬពាក់កណ្ដាលសម្រេចពីប្រទេសផ្សេង មកធ្វើប្រតិបត្តិការនិងការកែច្នៃអប្បបរមា និង/ឬត្រឹមតែបិទស្លាកសញ្ញាសម្គាល់ ថាមានដើមកំណើតនៅកម្ពុជា ដើម្បីទទួលបានការអនុគ្រោះពន្ធពីប្រទេសគោលដៅនាំចូលនោះទេ
- អនុវត្តតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសកម្មភាពដោះដូរទំនិញ ការរក្សាគុណភាព ការចាត់ថ្នាក់ទំនិញ ការធ្វើអធិការកិច្ចគុណភាពទំនិញ (Quality Control) រួមទាំងការរក្សាស្តង់ដាបរិស្ថានទាក់ទងនឹងការវេចខ្ចប់ និងការរក្សាទុកដាក់រហូតដល់ដំណាក់កាលដឹកជញ្ជូនទំនិញនាំចេញ។

## ជំពូក២៖ ក្រមសីលធម៌ វិន័យ និងបច្ចេកទេសវិជ្ជាជីវៈ នៃមន្ត្រីទទួលបន្ទុកអនុវត្តនីតិវិធីពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ

### ២.១. ក្រមសីលធម៌របស់មន្ត្រីទទួលបន្ទុកអនុវត្តនីតិវិធីក្នុងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ

ដើម្បីពង្រឹងការអនុវត្តបែបបទ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ មន្ត្រីត្រូវប្រកបដោយក្រមសីលធម៌ វិន័យ និងបច្ចេកទេសវិជ្ជាជីវៈក្នុងពេលបំពេញការងារ ដូចខាងក្រោម៖

### ២.១.១. ក្រមសីលធម៌ និងវិន័យ

- ត្រូវប្រកាន់ខ្ជាប់នូវភាពស្អាតស្អំ សុចរិតភាព ភាពទៀងត្រង់ និងត្រូវចៀសវាងការរើសអើងភេទ ជាតិសាសន៍ ឬសាសនាលើផលិតករ និង/ឬអ្នកនាំចេញ
- មិនត្រូវប្រមាថ ចំអក សម្លុត គំរាមកំហែង ឬប្រើពាក្យសំដីមិនសមរម្យ
- មិនត្រូវអនុវត្តការងារក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬគ្រឿងញៀន
- មិនត្រូវយកអាវុធ គ្រឿងផ្ទុះ និងវត្ថុធាតុ ឬសារធាតុដែលអាចបង្កគ្រោះថ្នាក់ចូលក្នុងទីតាំងបំពេញការងារ
- ត្រូវប្រកាន់ជំហរមិនលម្អៀង និងមិនត្រូវមានទំនាស់ផលប្រយោជន៍ជាមួយផលិតករ និង/ឬអ្នកនាំចេញ ដោយមិនឃុបឃិតជាមួយបុគ្គលពាក់ព័ន្ធផ្សេងទៀតក្នុងចេតនាគេចវេះ រារាំង និងក្លែងបន្លំដើមកំណើតទំនិញ
- មិនត្រូវស្នើសុំ ឬទទួលអត្ថប្រយោជន៍ អំណោយ និងសំណូក គ្រប់ទម្រង់ដូចជា ទឹកប្រាក់ សម្ភារ ទំនិញ ឬការផ្តល់អាទិភាព ដោយផ្ទាល់ ឬប្រយោល
- ត្រូវធានាថារាល់របាយការណ៍ និងកំណត់ហេតុការងារពាក់ព័ន្ធ មានភាពជាក់លាក់ ច្បាស់លាស់ មិនលម្អៀង និងភាពទទួលខុសត្រូវខ្ពស់ ប្រកបដោយគុណភាពសេវាកម្មវិជ្ជាជីវៈ។

### ២.១.២. បច្ចេកទេសវិជ្ជាជីវៈ

#### ២.១.២.១. តួនាទីនិងភារកិច្ចរបស់មន្ត្រីទទួលបន្ទុកចុះពិនិត្យ និងផ្ទៀងផ្ទាត់

- ត្រូវអនុវត្តជំនាញតាមការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីវិធានដើមកំណើតទំនិញ
- ត្រូវពិនិត្យផ្ទៀងផ្ទាត់ឯកសារ និងវិភាគព័ត៌មានដែលទទួលបានតាមបែបវិទ្យាសាស្ត្រ និងតាមរូបមន្តដែលមានចែងជាធរមាន ស្របតាមបែបបទនៃវិធានដើមកំណើតទំនិញ
- ត្រូវពិចារណាលើការបកស្រាយ និងការពន្យល់ហេតុផលរបស់ផលិតករ និង/ឬអ្នកនាំចេញ
- ការផ្តល់របាយការណ៍ និងការវាយតម្លៃថា មានឬមិនមានគុណវុឌ្ឍិគ្រប់គ្រាន់លើអនុលោមភាពដើមកំណើតទំនិញតាមការស្នើសុំ។

#### ២.១.២.២. តួនាទីនិងភារកិច្ចរបស់មន្ត្រីទទួលបន្ទុកចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ

- ត្រូវអនុវត្តជំនាញតាមការបណ្តុះបណ្តាលពាក់ព័ន្ធនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីវិធានដើមកំណើតទំនិញ
- ធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងវិនិច្ឆ័យសុក្រឹតភាពលើព័ត៌មានក្នុងរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃ ទទួលបានពីមន្ត្រីចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់
- ត្រូវអនុវត្តក្នុងដែនសមត្ថកិច្ច និងអាណត្តិក្នុងការសម្រេចចិត្តចេញ ឬមិនចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ដោយឈរលើមូលដ្ឋានរឹងមាំ និងច្បាស់លាស់ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ២.២. ឯករាជ្យភាព និងទំនាស់ផលប្រយោជន៍

- មិនស្ថិតក្រោមសម្ពាធ ឬបញ្ជាពីខាងក្រៅ ទោះបីជាដើម្បីផលប្រយោជន៍ ឬមិនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់ប្រសិទ្ធភាពការងារ
- មិនត្រូវទទួលយកផលប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឱ្យឱនថយដល់ភាពសុចរិត និងភាពស្មោះត្រង់ដែលធ្វើឱ្យប៉ះពាល់ដល់ការសម្រេចចិត្តក្នុងតួនាទីរបស់ខ្លួន
- មិនត្រូវជួយឬចូលរួមរៀបចំបញ្ជី ឬឯកសារពាក់ព័ន្ធឱ្យផលិតករ និង/ឬអ្នកនាំចេញ
- មិនត្រូវប្រើតួនាទីផ្លូវការរបស់ខ្លួនដើម្បីមានឥទ្ធិពល ឬបង្វែរនីតិវិធីរបស់រដ្ឋបាល សម្រាប់ជាផលប្រយោជន៍របស់ខ្លួន ឬគ្រួសារ។

## ២.៣. រក្សាការសម្ងាត់

- ត្រូវប្រកាន់ខ្ជាប់នូវការរក្សាការសម្ងាត់នូវព័ត៌មានរបស់ផលិតករ និង/ឬអ្នកនាំចេញ
- មិនត្រូវប្រើប្រាស់ព័ត៌មានសម្ងាត់របស់ផលិតករ និង/ឬអ្នកនាំចេញសម្រាប់បម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬសម្រាប់គោលបំណងមិនផ្លូវការ ឬសម្រាប់គោលបំណងទុច្ចរិតផ្សេងទៀត
- មន្ត្រីទទួលបន្ទុកអនុវត្តនីតិវិធីពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ដែលមិនអនុវត្តតាមនីតិវិធីប្រតិបត្តិស្តង់ដានេះ នឹងត្រូវទទួលរងនូវការដាក់ពិន័យ និង/ឬទណ្ឌកម្ម ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីវិធានដើមកំណើតទំនិញ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ២.៤. ក្រមសីលធម៌របស់ផលិតករ និងអ្នកនាំចេញ

ដើម្បីចូលរួមអនុវត្តបែបបទនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ផលិតករ និង/ឬអ្នកនាំចេញត្រូវសហការជាមួយនឹងមន្ត្រីបំពេញការងារ និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ដូចខាងក្រោម៖

- មិនត្រូវប្រើពាក្យសំដី អាកប្បកិរិយាមិនសមរម្យ ប្រមាថ ឬចំអកឡកឡាយ
- មិនត្រូវប្រើអំពើហិង្សា សម្លុត គំរាមកំហែង ឬដាក់សម្ពាធ ដោយផ្ទាល់ ឬដោយប្រយោល
- មិនត្រូវប្រើប្រាស់អាវុធគ្រប់ប្រភេទដើម្បីបន្លាច ឬគំរាម
- មិនត្រូវរារាំងមន្ត្រីបំពេញការងារចូលទៅទីតាំងរបស់ផលិតករ និង/ឬអ្នកនាំចេញ ដែលមកអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីវិធានដើមកំណើតទំនិញ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញជាធរមាន
- មិនត្រូវផ្តល់អំណោយ ឬសំណូក ដោយផ្ទាល់ ឬដោយប្រយោល ឬសន្យាផ្តល់អត្ថប្រយោជន៍ផ្សេងៗ
- មិនត្រូវឃុបឃិតជាមួយមន្ត្រី ក្នុងការរៀបចំបញ្ជីឯកសារក្នុងចេតនាក្លែងបន្លំដើមកំណើតទំនិញ
- មិនត្រូវថតសំឡេង រូបភាព ឬវីដេអូមន្ត្រីដែលបំពេញការងារ ដោយគ្មានការអនុញ្ញាត។

# ជំពូក៣៖ នីតិវិធីនៃការចុះត្រួតពិនិត្យ និងការស៊ើបអង្កេត

ការចុះត្រួតពិនិត្យ និងការស៊ើបអង្កេតដឹកនាំដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ រួមមាន៖ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ច តាមរយៈលិខិតបេសកកម្មរបស់ប្រធានស្ថាប័នពាក់ព័ន្ធ។

ការចុះត្រួតពិនិត្យ និងការស៊ើបអង្កេតអាចធ្វើឡើងតាមសំណូមពរ ឬបណ្តឹងរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ឬភាគីពាក់ព័ន្ធនានា ឬក្រោយពីទទួលបានរបាយការណ៍នៃការផ្ទៀងផ្ទាត់ថា មានហានិភ័យ។

### ៣.១. ការចុះត្រួតពិនិត្យលើកដំបូង

ការចុះត្រួតពិនិត្យលើកដំបូង នៅអាជីវកម្មដ្ឋាន ឬទីតាំងផលិត ត្រូវអនុវត្តដោយមន្ត្រីនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម។

### ៣.២. ការចុះត្រួតពិនិត្យ និងការស៊ើបអង្កេត

ការចុះត្រួតពិនិត្យ និងការស៊ើបអង្កេតនៅអាជីវកម្មដ្ឋាន ឬទីតាំងផលិត ត្រូវអនុវត្តដោយមន្ត្រីនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ច។

### ៣.៣. ចំនួនដងនៃការចុះត្រួតពិនិត្យ

ការចុះត្រួតពិនិត្យនៅអាជីវកម្មដ្ឋាន ឬទីតាំងផលិត អាចអនុវត្តតាមការចាំបាច់ ឬតាមសំណូមពរ ឬបណ្ដឹងរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ឬភាគីពាក់ព័ន្ធនានា ឬក្រោយពីទទួលបានរបាយការណ៍នៃការផ្ទៀងផ្ទាត់ថា មានហានិភ័យ។

### ៣.៤. ការជូនដំណឹងទៅផលិតករ និង/ឬអ្នកនាំចេញអំពីការចុះត្រួតពិនិត្យ

រាល់ការចុះត្រួតពិនិត្យ និង/ឬស៊ើបអង្កេត ត្រូវអនុវត្តនៅក្នុងម៉ោងការងាររដ្ឋ។

ការចុះអនុវត្តត្រួតពិនិត្យលើកដំបូងនៅតាមអាជីវកម្មដ្ឋាន ឬទីតាំងផលិត ត្រូវមានការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់ទីតាំង យ៉ាងយូរបំផុត ១ថ្ងៃមុន។

ការចុះត្រួតពិនិត្យ និងស៊ើបអង្កេតក្នុងករណីតាមសំណូមពរ ឬបណ្ដឹងរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ឬភាគីពាក់ព័ន្ធនានា អាចអនុវត្តដោយពុំចាំបាច់ជូនដំណឹងជាមុន។

### ៣.៥. លក្ខខណ្ឌនៃការចុះត្រួតពិនិត្យ និងស៊ើបអង្កេត

ការចូលទៅបំពេញភារកិច្ចត្រួតពិនិត្យ និងការស៊ើបអង្កេតនៅអាជីវកម្មដ្ឋាន ឬទីតាំងផលិត មន្ត្រីចុះត្រួតពិនិត្យ និង/ឬមន្ត្រីស៊ើបអង្កេតត្រូវគោរពតាមលក្ខខណ្ឌ ដូចខាងក្រោម៖

- ប្រើប្រាស់ឯកសណ្ឋានផ្លូវការដែលកំណត់ដោយក្រសួង
- បង្ហាញអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ និង
- លិខិតបញ្ជាបេសកកម្ម។

### ៣.៦. សិទ្ធិរបស់មន្ត្រីស៊ើបអង្កេត

មន្ត្រីស៊ើបអង្កេត ដែលទទួលការចាត់តាំងបំពេញភារកិច្ចចុះត្រួតពិនិត្យនៅតាមអាជីវកម្មដ្ឋាន ឬទីតាំងផលិត មានសិទ្ធិ និងអំណាច ដូចមានចែងក្នុងមាត្រា២៤ នៃច្បាប់ស្ដីពីវិធានដើមកំណើតទំនិញ។

### ៣.៧. នីតិវិធីនៃការចុះស៊ើបអង្កេត

ក្នុងកំឡុងពេលចុះបំពេញការងារ មន្ត្រីចុះស៊ើបអង្កេតត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

- ធ្វើការប្រជុំជាមួយម្ចាស់ឬតំណាងស្របច្បាប់របស់ម្ចាស់អាជីវកម្មដ្ឋាន ឬទីតាំងផលិត ដើម្បីបង្ហាញពីសមាសភាពមន្ត្រីចូលរួម ពីគោលបំណងនិងសកម្មភាពការងារដែលត្រូវអនុវត្ត និងពីការប្រមូលព័ត៌មានពាក់ព័ន្ធ

- ធ្វើការកត់ត្រាឱ្យបានលម្អិត និងច្បាស់លាស់នូវព័ត៌មាន ដើម្បីបំពេញកំណត់ហេតុយកសំណាក និងថតភស្តុតាង ដែលបានពិនិត្យឃើញនៅតាមទីកន្លែង ឬគោលដៅត្រួតពិនិត្យ ឬការស៊ើបអង្កេត
- ធ្វើការប្រជុំបូកសរុបលទ្ធផលត្រួតពិនិត្យ ជាមួយម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់អាជីកម្មដ្ឋាន ឬទីតាំងផលិត ដោយត្រូវធ្វើកំណត់ហេតុបញ្ជាក់ពីបញ្ហាដែលបានពិនិត្យឃើញ ឬសេចក្តីបង្គាប់ឱ្យមានការកែតម្រូវជាកំហិត
- ផ្ទៀងផ្ទាត់ខ្លឹមសារកំណត់ហេតុ ដោយមានការចូលរួមទទួលដឹងឮពីម្ចាស់ ឬតំណាងស្របច្បាប់របស់ម្ចាស់អាជីវកម្មដ្ឋាន ឬទីតាំងផលិត តាមរយៈការអាន ការបកប្រែ ការផ្តិតស្នាមមេដៃលើកំណត់ហេតុ និងការផ្តល់ច្បាប់ចម្លងទៅគ្រប់តំណាងចូលរួម។

## ៣.៨. ការអនុវត្តលើបទល្មើសជាក់ស្តែងដែលរកឃើញក្នុងពេលចុះស៊ើបអង្កេត

ក្នុងករណីពេលចុះអនុវត្តការស៊ើបអង្កេតរកឃើញបទល្មើសជាក់ស្តែងបង្កណាមួយ មន្ត្រីស៊ើបអង្កេតត្រូវអនុវត្តនីតិវិធី ដូចខាងក្រោម៖

- ប្រមូលវត្ថុតាង ឬសំណាកពាក់ព័ន្ធនឹងបទល្មើស និងធ្វើកំណត់ហេតុដោយឡែកអំពីបទល្មើសជាក់ស្តែងដែលបានរកឃើញ
- ចាត់វិធានការផ្អាកជាបណ្តោះអាសន្ននៃការអនុញ្ញាតនាំចេញ។

## ៣.៩. ការរក្សាការសម្ងាត់នៃព័ត៌មាន

មន្ត្រីចុះស៊ើបអង្កេត ត្រូវមានការទទួលខុសត្រូវក្នុងការរក្សាការសម្ងាត់នៃព័ត៌មានឯកសារកំណត់ត្រា រូបភាព និងលទ្ធផលវិភាគសំណាក ដែលប្រមូលបានក្នុងពេលធ្វើការត្រួតពិនិត្យ ឬការស៊ើបអង្កេត លើកលែងតែមានការអនុញ្ញាតដោយច្បាប់ ឬការបង្គាប់របស់តុលាការ។

## ៣.១០.ប្រតិបត្តិការក្រោយការចុះស៊ើបអង្កេត

ក្រោយការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការស៊ើបអង្កេត ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យក្នុងរយៈពេលមិនលើសពី ៣ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចុះបំពេញការងារ។

## ៣.១១.វិធានការបន្តក្រោយការចុះស៊ើបអង្កេត

ក្រោយការពិនិត្យ និងសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង មន្ត្រីស៊ើបអង្កេតត្រូវបន្តការអនុវត្តវិធានការជាបន្ទាន់ទៅតាមអនុសាសន៍ណែនាំ ឬសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង។

## ៣.១២.ទណ្ឌកម្មរដ្ឋបាល

មន្ត្រីស៊ើបអង្កេត ដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការអនុវត្តប្រកាសស្តីពីនីតិវិធីស្នើសុំនិងការចេញលិខិតបញ្ជាក់ដើមកំណើតទំនិញ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់ជាធរមាន។

ម្ចាស់ ឬតំណាងស្របច្បាប់របស់អាជីវកម្មដ្ឋាន ឬទីតាំងផលិត ដែលរារាំងការចូលក្នុងទីតាំង ឬពុំព្រមផ្តល់កិច្ចសហការក្នុងការបំពេញភារកិច្ចរបស់មន្ត្រីស៊ើបអង្កេត ដូចមានចែងក្នុងនីតិវិធីប្រតិបត្តិស្តង់ដានេះ ត្រូវរងទណ្ឌកម្ម ឬទោស អនុលោមតាមច្បាប់ស្តីពីវិធានដើមកំណើតទំនិញ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។



ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *